ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០ សរណន

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩

# សារាចរណែនាំ
# ស្តីពី
# នីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល

ទោះបីជាច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីកាសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល សារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍ជ្រើសរើសអោយចូលក្នុងក្របខណ្ឌរដ្ឋ និងគោលការណ៍ជ្រើសរើសបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងស្ថាប័ននានា សារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការជ្រើសរើស និងតែងតាំងមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋានផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់ដើម្បីធ្វើអោយរដ្ឋបាលរបស់រដ្ឋមានលក្ខណៈអព្យាក្រឹត តម្លាភាព និងអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ការអនុវត្តន៍របស់ក្រសួងស្ថាប័ន និងខេត្ត-ក្រុងមួយចំនួនក្នុងការជ្រើសរើសអោយចូលក្នុងក្របខណ្ឌរដ្ឋ និងការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងក្របខណ្ឌមុខងារសាធារណៈ នៅតែមានបាតុភាពមិនប្រក្រតីដែលផ្ទុយនឹងគោលការណ៍ និងនីតិវិធីដែលបានកំណត់ហើយមិនទាន់មានលក្ខណៈឯកភាពគ្នានៅឡើយ ។

ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ លិខិតបទដ្ឋាន និង លុបបំបាត់បាតុភាពមិនប្រក្រតីខាងលើ រាជរដ្ឋាភិបាលសូមធ្វើការណែនាំបន្ថែមដូចខាងក្រោម ៖

**១. ការតែងតាំងមន្ត្រីរាជការស៊ីវិលនៅក្រសួង-ស្ថាប័ន** :

- ត្រូវបន្តអនុវត្តអោយបានត្រឹមត្រូវតាមចំណុចទី២ ស្តីអំពីការតែងតាំងមុខតំណែងដែលកំណត់ក្នុងសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ១៥ ខែ ខែ មីនា ឆ្នាំ ១៩៩៩ ពោលគឺ :
  - ក- ការតែងតាំងអោយកាន់មុខតំណែងណាមួយនៃមុខងារសាធារណៈ របស់ក្រសួងស្ថាប័ន ជាគោលការណ៍ត្រូវអនុវត្តចំពោះមន្ត្រីរាជការក្របខណ្ឌនៃក្រសួងស្ថាប័ននោះ ។
  - ខ- ការតែងតាំងត្រូវផ្អែកលើសំណូមពរ ភារកិច្ចជាក់ស្តែង សញ្ញាប័ត្រជំនាញ បទពិសោធន៍ការងាររបស់សាមីជន អោយសមស្របទៅតាមតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រសួងនីមួយៗ ។
  - គ- ការតែងតាំងអោយកាន់មុខតំណែងណាមួយ ក្នុងមុខងារសាធារណៈ ត្រូវអនុវត្តអោយបានសមស្របទៅតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលមានចែងក្នុងមាត្រា ២៨ ជំពូក ទី ៣ ស្តីពីសិទ្ធិក្នុងការតែងតាំង ។
- ត្រូវធ្វើការពិគ្រោះយោបល់អោយបានឯកភាពគ្នា ជៀសវាងដាច់ខាតមិនអោយមានបាតុភាពនៅក្នុងស្ថាប័នរបស់ខ្លួនមុននឹងលើកសំណើតែងតាំង ឬធ្វើសេចក្តីសម្រេចជាស្ថាពរ ។
- រាល់លិខិតបទដ្ឋានឯកត្តជនស្តីពីការតែងតាំងមន្ត្រីរាជការស៊ីវិល ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ត្រូវដាក់ឆ្លងជាមុនដើម្បីផ្ទៀងផ្ទាត់ផ្នែករដ្ឋបាលដោយរដ្ឋលេខាធិខាដ្ឋានមុខងារសាធារណៈ និងផ្នែកថវិកាដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលត្រូវចុះទិដ្ឋាការរៀងៗខ្លួន ។
- លិខិតបទដ្ឋានឯកត្តជនណាដែលគ្មានទិដ្ឋាការនោះ ត្រូវទុកជានិរាករណ៍ ។

**២. ការតែងតាំងប្រធានមន្ទីរជំនាញខេត្ត-ក្រុង** :

- ការផ្តួចផ្តើមលិខិតតែងតាំងត្រូវធ្វើឡើងដោយក្រសួងស្ថាប័នជំនាញ ។
- ត្រូវធ្វើការពិគ្រោះយោបល់ អោយបានឯកភាពគ្នាក្នុងក្រសួងស្ថាប័ន ដើម្បីកំណត់យកបេក្ខជនដែលត្រូវតែងតាំង ។
- បន្ទាប់មកត្រូវពិគ្រោះយោបល់លើបេក្ខជនដែលត្រូវតែងតាំងនោះ ជាមួយអភិបាលខេត្ត-ក្រុងសាមី ហើយអភិបាលខេត្ត-ក្រុងសាមីនោះត្រូវធ្វើការពិគ្រោះយោបល់អោយមានការឯកភាពគ្នា ក្នុងជួរថ្នាក់ដឹកនាំខេត្ត-ក្រុង មុននឹងផ្តល់យោបល់ឆ្លើយតប ។
- ក្នុងករណីមិនមានការឯកភាពរវាងក្រសួងស្ថាប័នសាមីជាមួយនឹងខេត្ត-ក្រុង នោះអភិបាលខេត្តក្រុងត្រូវលើកសំណើជូនក្រសួងមហាផ្ទៃ ដើម្បីជួយធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័នសាមី ។
- ក្នុងករណីមិនអាចសម្របសម្រួលបាន ក្រសួងមហាផ្ទៃ ឬក្រសួងស្ថាប័នសាមីត្រូវលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

៣. ក្នុងករណីពិនិត្យឃើញថា លិខិតបទដ្ឋានឯកត្តជនស្តីពីការតែងតាំងមន្ត្រីរាជការរបស់ក្រសួងស្ថាប័នធ្វើឡើងផ្ទុយនឹងច្បាប់ ឬលិខិតបទដ្ឋានជាធរមាម ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិកាដ្ឋានមមុខងារសារធារណៈត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីសុំការអនុគ្គញ្ញាតលុបចោល ហើយត្រូវធ្វើការណែនាំក្រសួងស្ថាប័ននោះធ្វើអោយបានត្រឹមត្រូវឡើងវិញ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួងស្ថាប័ន និងខេត្ត-ក្រុង ត្រូវខិតខំអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ